## សុន្ទរកថាស្វាគមន៍

## របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ក្នុងកិច្ចប្រជុំលើកទី ១៩ នៃ

## គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍

## វិមានរដ្ឋាភិបាល

## ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២

*- លោកជំទាវ ឯកឧត្តម ជាសហសេវិកក្នុងរាជរដ្ឋាភិបាល*

*- លោកជំទាវ ឯកឧត្តម ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ប្រធានស្ថានតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល*

*- លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

១- ជាបឋម ខ្ញុំមានសេចក្តីសោមនស្សរីករាយនិងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់លោកជំទាវ ឯកឧត្តម ជាសហសេវិកនៃរាជរដ្ឋាភិបាល លោកជំទាវ ឯកឧត្តមឯកអគ្គរដ្ឋទូត លោកនិងលោកស្រីតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងឯកឧត្តម លោកស្រី អស់លោក ក្នុងកិច្ចប្រជុំលើកទី១៩នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) នៅវិមានរដ្ឋាភិបាលនាពេលព្រឹកនេះ ។ មុននឹងចាប់ផ្តើម ខ្ញុំសូមជម្រាបអង្គប្រជុំថា គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) ក្រោមកិច្ចដឹកនាំរបស់រដ្ឋមន្ត្រី **ឈៀង យ៉ាណារ៉ា** បានរៀបចំការងារត្រៀមជាច្រើនសម្រាប់កិច្ចប្រជុំនេះ ដោយបានសហការយ៉ាងជិតស្និទ្ធជាមួយនឹងប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ ។

២- កិច្ចប្រជុំរបស់យើងនាព្រឹកនេះត្រូវបានរៀបចំឡើង ក្នុងខណៈពេលដែលភាពដៃគូក្នុងកិច្ចអភិវឌ្ឍន៍បាននិងកំពុងដំណើរការប្រកបដោយផ្លែផ្កា និងក្នុងខណៈពេលដែលយើងបានត្រៀមខ្លួនជាស្រេចសម្រាប់រួមគ្នាដោះស្រាយបញ្ហាប្រឈមថ្មីៗដែលយើងកំពុងជួបប្រទះ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចពិភាក្សានាពេលព្រឹកនេះនឹងផ្តល់កាលានុវត្តភាពសម្រាប់រំលេចឱ្យឃើញនូវវឌ្ឍនភាពដែលយើងបានសម្រេចរួមគ្នា ក៏ដូចជាពិភាក្សាលំអិតផងដែរអំពីជំហានការងារដែលត្រូវអនុវត្តបន្ត ក្នុងនាមជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍។ ភាពជាដៃគូគឺជាសមាសភាគដ៏សំខាន់មួយនៃដំណើរការអភិវឌ្ឍជាតិ នាយុគ្គសម័យថ្មីនេះ ។ ជាការពិតណាស់ ព្រះរាជាណាចក្រកម្ពុជាមានមោទនៈភាពដែលបានធ្វើជាប្រធានកិច្ចប្រជុំអាស៊ាន (ASEAN) ក្នុងឆ្នាំ២០១២នេះ ។ ក្នុងបរិការណ៍នេះ សមាហរណកម្មក្នុងតំបន់គឺជាប្រធានបទស្នូលក្នុងការឈានទៅកាត់បន្ថយគម្លាតនៃការអភិវឌ្ឍន៍ ដើម្បីឈានទៅបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន នាឆ្នាំ២០១៥ (ASEAN Economic Community 2015) ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

៣- កិច្ចប្រជុំព្រឹកនេះមានរបៀបវារៈជាច្រើន ។ ប៉ុន្តែ មុននឹងចាប់ផ្តើម ខ្ញុំយល់ថា យើងមានភាពចាំបាច់ក្នុងការរំលឹកឡើងវិញនូវគោលការណ៍មួយចំនួនស្តីពីភាពជាដៃគូ ដែលយើងបានប្តេជ្ញារួមគ្នាអនុវត្ត ។ នៅក្នុងវេទិកាកំពូលលើកទី៤ ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ នៅទីក្រុងប៊ូសាននៃសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ កន្លងមក តំណាងស្ថាប័ននិងប្រទេសដៃគូអភិវឌ្ឍន៍បានអះអាងសារជាថ្មីម្តងទៀត អំពីការប្តេជ្ញារបស់ខ្លួន ក្នុងការពង្រឹងការអនុវត្តគោលការណ៍ស្តីពីភាពជាដៃគូ ។ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាដៃគូអភិវឌ្ឍន៍ដែលមានតំណាងនៅទីនេះ បានអនុមតិ «ភាពជាដៃគូទីក្រុងប៊ូសានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព – Busan Partnership for Effective Development Cooperation» ។ វេទិកាអន្តរជាតិជាច្រើន ដូចជាកិច្ចប្រជុំកំពូល Rio+២០ (Rio+20) នាថ្ងៃទី២០-២២ ខែមិថុនា ឆ្នាំ២០១២ និងវេទិកាកិច្ចសហប្រតិបត្តិការសម្រាប់កិច្ចអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UN Development Cooperation Forum -- UNDCF) នាថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ២០១២ បានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាទាំងនេះ ដើម្បីរំលឹកអំពីភាពចាំបាច់ក្នុងការស្វែងរកដំណោះស្រាយសម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រឈមសាកលនេះ ។ សារសំខាន់មួយដែលបានលើកឡើងយ៉ាងច្បាស់ និងជាច្រើនលើកក្នុងវេទិកាអន្តរជាតិទាំងនេះ គឺភាពចាំបាច់ក្នុងការផ្លាស់ប្តូរទស្សនៈ (Mindset) និង ឥរិយាបថ (Behavior) ដើម្បីធានាចីរភាពនៃភាពជាដៃគូ សម្រាប់ឈានឆ្ពោះទៅសម្រេចលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ។ របៀបរបបប្រតិបត្តិតាមទម្លាប់កន្លងមក (Business as usual) មិនអាចផ្តល់នូវលទ្ធផល និងអនាគតដ៏ភ្លឺស្វាងដែលយើងទាំងអស់គ្នាចង់បាន ហើយដែលយើងបានប្តេជ្ញាទាំងអស់គ្នានៅកិច្ចប្រជុំកំពូលទីក្រុងប៊ូសាន ។ ជានិច្ចជាកាល យើងរមែងតែធ្វើការប្តេជ្ញាដើម្បីកែប្រែរបៀបរបបប្រតិបត្តិរបស់យើង ។ ប៉ុន្តែ ដៃគូអភិវឌ្ឍន៍មិនបានអនុវត្តជាក់ស្តែងនិងទាំងស្រុងទេ នូវអ្វីដែលខ្លួនបានប្តេជ្ញានោះឡើយ ទាំងនៅកម្រិតប្រទេស ទាំងនៅកម្រិតសាកល ដូចដែលរបាយការណ៍ឆ្នាំ២០១១របស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OEDC) ស្តីពីការតាមដានការអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសឆ្នាំ២០០៥ ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ បានបញ្ជាក់ថា ដៃគូអភិវឌ្ឍន៍ត្រូវធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយមួយ ដើម្បីសម្រេចឱ្យបាននូវការប្តេជ្ញារបស់ខ្លួន ។

៤- កិច្ចប្រជុំ GDCC របស់យើង នាពេលនេះ ត្រូវផ្តែកលើស្មារតីនៃភាពជាដៃគូ ។ កិច្ចការសំខាន់ក្នុងរបៀបវារៈរបស់យើង គឺការអនុមតិលើសូចនាករតាមដានរួមគ្នា (JMI) ។ ដូចលោកជំទាវ ឯកឧត្តម លោកស្រី អស់លោកបានជ្រាបហើយថា សូចនាករនេះត្រូវបានដាក់ឱ្យ អនុវត្តចាប់តាំងពីឆ្នាំ២០០៤ ហើយបានក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាព មិនត្រឹមតែសម្រាប់រំលេចពីការប្រឹងប្រែងរួមគ្នា ទាំងធនធាន ទាំងបច្ចេកទេស ដើម្បីឈានទៅសម្រេចបានលទ្ធផលប៉ុណ្ណោះទេ ប៉ុន្តែ វាគឺជាក្របខ័ណ្ឌសម្រាប់ឆ្លុះបញ្ចាំង និងសម្រាប់ពិចារណាឱ្យកាន់តែទូលំទូលាយ ដើម្បីធានានិងបង្កើនប្រសិទ្ធភាពនៃភាពជាដៃគូ ។ ខ្ញុំសូមគូសបញ្ជាក់ថា សូចនាករតាមដានរួមគ្នាដែលជារបៀបវារៈនៃការពិនិត្យ និងអនុមតិនាពេលនេះ ត្រូវបានពិភាក្សារួមគ្នាជាច្រើនលើកច្រើនសារ ក្នុងរយៈពេល៣ខែចុងក្រោយនេះ ដោយគិតទាំងអង្គវិបស្សនាដែលបានរៀបចំដោយរាជរដ្ឋាភិបាល ដែលមាន គ.ជ.នា/ក.អ.ក ជាសេនាធិការ កាលពីថ្ងៃ២០-២១ ខែសីហា ឆ្នាំ២០១២ នៅក្រុងព្រះសីហនុ កន្លងមកផងដែរ ។ ក្នុងស្មារតីនេះ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា យើងទាំងអស់គ្នាប្រាកដជាមានសូចនាករតាមដានរួមគ្នាប្រកបដោយគុណភាព ដែលអាចប្រើប្រាស់ជាមគ្គុទេសន៍សម្រាប់ដឹកនាំកិច្ចប្រឹងប្រែងរបស់យើង ដើម្បីឈានសម្រេចភាពជាដៃគូដោយផ្តោតលើលទ្ធផល ។ សូចនាករតាមដានរួមគ្នានេះបានតម្រូវឱ្យមានតម្លាភាព ក្នុង

ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ទាំងរបស់រាជរដ្ឋាភិបាល ទាំងពីប្រភពហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងតម្រូវឱ្យមានលទ្ធផលជាក់ស្តែងក្នុងការអនុវត្តការប្តេជ្ញានានារបស់ខ្លួន ។

៥- ក្នុងកិច្ចប្រជុំ GDCC លើកនេះ យើងក៏ត្រូវពិភាក្សាផងដែរអំពីដំណើរការរៀបចំឯកសារគោលនយោបាយចំនួន ២ ដែលជាស្នូលនៃការងារភាពជាដៃគូរបស់យើង ។ ឯកសារគោលនយោបាយទីមួយ គឺឯកសារស្តីពី «ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨» ដែលត្រូវចាប់ផ្តើមរៀបចំនាឆ្នាំ២០១៣ ។ ឯកសារគោលនយោបាយនេះនឹងបង្ហាញពីវឌ្ឍនភាព និងបទពិសោធន៍ ក៏ដូចជាសម្រាប់ណែនាំការវិភាជន៍ធនធានសម្រាប់បណ្តាវិស័យអាទិភាពផងដែរ ។ ឯកសារគោលនយោបាយទីពីរគឺ «យុទ្ធសាស្រ្តស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ» ។ នេះគឺជាវិធាននៃល្បែងដ៏សំខាន់សម្រាប់ណែនាំការអនុវត្តភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ហើយក៏ជាឧបករណ៍សម្រាប់កៀរគរហិរញ្ញប្បទានពីក្រៅប្រទេស ។ ក្នុងដំណើរការនៃការរៀបចំឯកសារគោលនយោបាយទាំង ២ ខាងលើ យើងត្រូវផ្តោតការយកចិត្តទុកដាក់ដល់ការអនុវត្តគោលការណ៍ស្តីពីតម្លាភាព ដែលជាមូលដ្ឋានគ្រឹះក្នុងការពង្រឹងកិច្ចការរបស់យើងនាពេលអនាគត ក៏ដូចជាពង្រឹងភាពជាដៃគូជាមួយនឹងតួអង្គអភិវឌ្ឍន៍ដទៃទៀតផងដែរ ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

៦- បទពិសោធន៍ដែលទទួលបានកន្លងមក តាមរយៈភាពជាដៃគូក្នុងការរៀបចំនិងការអនុវត្តសូចនាករតាមដានរួមគ្នា ក៏ដូចជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម គឺភាពចាំបាច់ក្នុងការធានាឱ្យមានតម្លាភាព (Transparency) និងភាពបើកទូលាយ (Openess) ក្នុងភាពជាដៃគូសម្រាប់អភិវឌ្ឍន៍ (Development Partnership) ។ ពីកិច្ចប្រជុំកម្រិតសាកលមួយទៅកិច្ចប្រជុំកម្រិតសាកលមួយទៀត ពិសេសពីកិច្ចប្រជុំនៅប៊ូសាន ទៅកិច្ចប្រជុំនៅប៉ារីស និងបន្ទាប់មកកិច្ចប្រជុំនៅទីក្រុងញ៉ូវយក នាឆ្នាំ២០១២ សារគន្លឹះមួយដែលពាក់ព័ន្ធនឹងតម្លាភាពនៃធនធានរបស់ដៃគូអភិវឌ្ឍន៍ គិតចាប់ពីប្រភពនៃធនធានរហូតដល់លទ្ធផលនៃការប្រើប្រាស់ធនធាន (Transparency from source to results) ត្រូវបានរំលឹកឡើងជាច្រើនលើកច្រើនសារ ។ រាជរដ្ឋាភិបាលសូមគូសបញ្ជាក់សារៈសំខាន់ និងតម្រូវការនៃតម្លាភាពធនធាន (Resource Transparency) ក្នុងកិច្ចអភិវឌ្ឍន៍កម្ពុជា ។ កន្លងមក យើងបានសម្រេចវឌ្ឍនភាពខ្លះៗ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងការធានាឱ្យមានតម្លាភាពនៃធនធាន ទាំងធនធានក្នុងស្រុក ធនធានរបស់ដៃគូអភិវឌ្ឍន៍ខ្លះ ។ កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្តាក្រសួងនិងស្ថាប័នពាក់ព័ន្ធក្នុងក្របខ័ណ្ឌនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឆ្លុះបញ្ចាំងអំពីភាពកាន់តែល្អប្រសើរឡើងនៃតម្លាភាពធនធាន តាមរយៈកំណែទម្រង់ថវិកា ការកែលម្អប្រព័ន្ធព័ត៌មាន និងការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ដែលទាំងនេះបានចូលរួមយ៉ាងសំខាន់ក្នុងការពង្រឹងប្រព័ន្ធផែនការ ដើម្បីឈានទៅសម្រេចលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ (Development Results) ។ ទន្ទឹមនឹងនេះ ប្រព័ន្ធព័ត៌មានស្តីពីហិរញ្ញប្បទានពីក្រៅប្រទេសត្រូវបានកែលម្អជាជំហានៗ ដោយមានការខិតខំស្វិតស្វាញ និងរន្ទើនពីសំណាក់ គ.ជ.នា/ក.អ.ក ក្នុងការប្រមូលទិន្នន័យ និងកត់ត្រាលំហូរហិរញ្ញប្បទានពីក្រៅប្រទេសទាំងនេះ ។ ប្រការនេះទាមទារឱ្យមានការខិតខំប្រឹងប្រែងរបស់ គ.ជ.នា/ក.អ.ក បន្ថែមទៀត ហើយខ្ញុំសូមឱ្យដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់យកចិត្តទុកដាក់ ចូលរួមកិច្ចការនេះ របស់ គ.ជ.នា/ក.អ.ក ។ នេះមានន័យថា រាជរដ្ឋាភិបាលត្រូវកត់ត្រាឱ្យបានច្បាស់លាស់អំពីហិរញ្ញប្បទាន គិតចាប់ពីប្រភពដើមនៃហិរញ្ញប្បទានទាំងនេះ រហូតដល់សមិទ្ធផលដែលសម្រេចបាន ។ យើងទាំងអស់គ្នាពិតជាមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការរៀបចំ និងចែករំលែកព័ត៌មាន ដោយ

ត្រូវបញ្ជាក់ឱ្យច្បាស់ពីប្រភពហិរញ្ញប្បទាន ពីរបៀបរបបនៃការគ្រប់គ្រងហិរញ្ញប្បទាន ព្រមទាំងលទ្ធផលនៃការប្រើប្រាស់ហិរញ្ញប្បទានទាំងនេះ ។ ក្នុងស្មារតីនេះ និងក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលពិតជាមានបំណងកត់ត្រាឱ្យបានពេញលេញនូវហិរញ្ញប្បទានសហប្រតិបត្តិការទៅក្នុងថវិការដ្ឋ ។ តម្លាភាពក្នុងការប្រើប្រាស់ធនធានទាំងនេះ នឹងនាំមកនូវការកែលម្អកម្មវិធីនីយកម្ម និងការវិភាជន៍ធនធាន ដែលអាចជួយលើកកម្ពស់លទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ។ ប៉ុន្តែ ការឈានទៅសម្រេចគោលដៅនេះ តម្រូវ ខាងរាជរដ្ឋាភិបាល ឱ្យមានការចូលរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង គ.ជ.នា/ក.អ.ក នៅក្នុងកិច្ចដំណើរការទាំងមូល ដោយគិតចាប់ពីការរៀបចំផែនការ ថវិកា រហូតដល់ការអនុវត្តធនធានរបស់គម្រោងឬកម្មវិធី ។ អង្គវិបស្សនារបស់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានប្រព្រឹត្តទៅ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៨-១៩ ខែសីហា ឆ្នាំ ២០១២ កន្លងមក និងកិច្ចប្រជុំនាពេលព្រឹកនេះនឹងផ្តល់កាលានុវត្តភាពបន្ថែមទៀត សម្រាប់ពិភាក្សាអំពីវឌ្ឍនភាព ក៏ដូចជាសម្រាប់ព្រមព្រៀងគ្នាលើសកម្មភាពចាំបាច់នានា និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធទាំងអស់ ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

៧- ក្នុងកិច្ចប្រជុំ GDCC លើកនេះ យើងខ្ញុំមានក្តីសោមនស្សរីករាយ នឹងជម្រាបអង្គប្រជុំថា រាជរដ្ឋាភិបាលនឹងជូនព័ត៌មានស្តីពីការអនុវត្តបទបញ្ជា លេខ ០១ ប.ប របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ។ ដូចយើងទាំងអស់គ្នាបានជ្រាបច្បាស់ហើយថា **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានដាក់ចេញវិធានការជាច្រើន និងដឹកនាំអនុវត្តដោយផ្ទាល់ ជាអគ្គបញ្ជាការ ដោយមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងនគរូបនីយកម្ម រៀបចំដែនដី និងសំណង់ ជាសេនាធិការ សម្រាប់អនុវត្តបទបញ្ជានេះនៅទូទាំងប្រទេស ។ ភាពស្មុគ្រស្មាញនៃបញ្ហាដីធ្លី ដែលរាជរដ្ឋាភិបាលកំពុងប្រឈមដោះស្រាយ និងចរិតយូរអង្វែងនៃវិធានការអនុវត្តបទបញ្ជា លេខ ០១ ប.ប បានបញ្ជាក់ថា មិនទាន់ដល់ពេលសមស្របដែលអនុញ្ញាតឱ្យមានការពិភាក្សាតាមទម្រង់ផ្លូវការណាមួយបានឡើយ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏រាជរដ្ឋាភិបាលយល់ពីសារៈប្រយោជន៍ក្នុងការចែករំលែកព័ត៌មានបឋមស្តីពីអភិក្រម វិធានការ និងលទ្ធផលបឋម ដែរ ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

៨- យើងទទួលស្គាល់គោលការណ៍គ្រឹះស្តីពីតម្លាភាពនៅក្នុងកិច្ចប្រជុំនាព្រឹកនេះ ។ ប៉ុន្តែ អនុសាសន៍របស់ខ្ញុំបានផ្តោតទៅលើភាពចាំបាច់នៃការបន្តចែករំលែកព័ត៌មាន និងការពិភាក្សាបន្ថែមទៀត ពិសេសការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមករវាងកិច្ចប្រជុំរួមគ្នា ដូចជាកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នាពេលនេះ (GDCC) និងកិច្ចប្រជុំកម្រិតទ្វេភាគី ដែលជាទូទៅ ដឹកនាំដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាថាកិច្ចប្រជុំទ្វេភាគីត្រូវបានដំណើរការជាប្រចាំ សម្រាប់ពិនិត្យអំពីវឌ្ឍនភាពការងារក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ការវិភាជន៍ធនធាន និងការពង្រឹងភាពជាដៃគូ ព្រមទាំងលទ្ធផលដែលសម្រេចបាន ។

៩- ភាពជាដៃគូជាមួយនឹងសហគមន៍អង្គការមិនមែនរដ្ឋាភិបាល ក៏មានសារៈសំខាន់ណាស់ដែរ ម៉្យាងដោយសារទំហំហិរញ្ញប្បទានដែលពួកគេបានកៀរគរ និងគ្រប់គ្រង និងម៉្យាងទៀត ដោយសារតួនាទីសំខាន់របស់ពួកគេក្នុងការចូលរួម

ផ្តល់សេវាសាធារណៈក្នុងវិស័យជាច្រើន ។ ក្នុងស្មារតីនេះ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** បាន កោតសរសើរចំពោះការឆ្លើយតបបានទាន់ពេលវេលា និងកិច្ចសហការដ៏មានប្រសិទ្ធភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ជាមួយនឹងរាជរដ្ឋាភិបាល និងស្ថាប័នជាតិពាក់ព័ន្ធដទៃទៀត ក្នុងការជួយសង្គ្រោះប្រជាជនដែលរងគ្រោះដោយសារទឹក ជំនន់ នាឆ្នាំ២០១១កន្លងមក ហើយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបញ្ជាក់អំពីការរៀបចំឱ្យមានកិច្ចពិគ្រោះយោបល់ ប្រចាំឆ្នាំ ដើម្បីធានាថា រាល់ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលមានសង្គតិភាពជាមួយនឹងអាទិភាពអភិវឌ្ឍន៍របស់ ប្រទេស ។ ក្នុងស្មារតីនេះ ខ្ញុំមានសេចក្តីសោមនស្សជម្រាបជូនអង្គប្រជុំឱ្យបានជ្រាបថា ឯកសារណែនាំស្តីពីកិច្ចពិគ្រោះ យោបល់រវាងរាជរដ្ឋាភិបាលជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលបានពិភាក្សានិងឯកភាពគ្នាកន្លងមក ត្រូវបាន អនុមតិដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

១០- មុននឹងចាប់ផ្តើមកិច្ចប្រជុំរបស់យើងនាពេលនេះ ខ្ញុំសូមអញ្ជើញឯកឧត្តម Douglas Broderick ប្រធានសម្រប សម្រួលប្រព័ន្ធអង្គការសហប្រជាជាតិ ដែលត្រូវបានជ្រើសតាំងជាប្រធានសម្របសម្រួលថ្មីរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីផ្តល់ មតិស្វាគមន៍ ។

*សូមអរគុណ !*